# ព្រះរាជក្រម

នស/រកម/០៣១៣/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១២៦/០០១/២០១៣ កបធ.ច ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ
# នៃឧត្តមក្រុមប្រឹក្សាការពារជាតិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតឧត្ដមក្រុមប្រឹក្សាការពារជាតិ ដើម្បីជានាការពាររដ្ឋធម្មនុញ្ញ ការពារឯករាជ្យជាតិ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងធានាការអនុវត្តតួនាទី ភារកិច្ច សមត្ថកិច្ចរបស់កងយោធពលខេមរភូមិន្ទ ព្រមទាំងពិនិត្យនិងអនុម័តគោលនយោបាយការពារជាតិនិងផែនការការពារជាតិ ។

## ជំពូកទី ២
## សមាសភាព

**មាត្រា ២.-**

ឧត្ដមក្រុមប្រឹក្សាការពារជាតិ មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | ព្រះអធិបតី |
| - នាយករដ្ឋមន្ត្រី | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | សមាជិក ។ |

**មាត្រា ៣.-**

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្ដមក្រុមប្រឹក្សាការពារជាតិ ។ ព្រះអង្គទ្រង់មានព្រះរាជសិទ្ធិ ចាត់តាំងនាយករដ្ឋមន្ត្រីជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ឲ្យធ្វើជាអធិបតីនៃអង្គប្រជុំរបស់ឧត្ដមក្រុមប្រឹក្សាការពារជាតិ ។

## ជំពូកទី ៣
## តួនាទីនិងភារកិច្ច

**មាត្រា ៤.-**

ឧត្ដមក្រុមប្រឹក្សាការពារជាតិ មានតួនាទីដូចតទៅ ៖

- ធានាការពាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ធានាការពារឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា

- ជានាអព្យាក្រឹតភាពនៃការអនុវត្តតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់កងយោធពលខេមរភូមិន្ទ
- ជានាការអនុវត្តគោលនយោបាយការពារជាតិនិងផែនការការពារជាតិ ។

**មាត្រា ៥.–**

ឧត្តមក្រុមប្រឹក្សាការពារជាតិ មានភារកិច្ចដូចតទៅ ៖

- ពិនិត្យនិងអនុម័តគោលនយោបាយការពារជាតិនិងផែនការការពារជាតិ
- ផ្តល់យោបល់ជាចាំបាច់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលទាក់ទងនឹងការរៀបចំកិច្ចការពារជាតិ ការទទួល ឬការដាក់ឲ្យនិរាករណ៍រាល់អនុសញ្ញា សន្ធិសញ្ញា កតិកាសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងលើវិស័យយោធា
- វាយតម្លៃសភាពការណ៍ក្នុងការដាក់ប្រទេសជាតិឲ្យស្ថិតក្នុងភាពអាសន្ន ឬសង្គ្រាម ដើម្បីដំណើការ នីតិវិធីស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ
- ពិនិត្យនិងអនុម័តផែនការនិងរបាយការណ៍នានារបស់អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាការពារជាតិ ។

## ជំពូកទី ៤
## ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ

**មាត្រា ៦.–**

ឧត្តមក្រុមប្រឹក្សាការពារជាតិត្រូវធ្វើការកោះប្រជុំសាមញ្ញយ៉ាងតិច ១ (មួយ) ដង ក្នុង ១ (មួយ) ឆ្នាំ តាមសេចក្តីអញ្ជើញពីព្រះមហាក្សត្រជាព្រះអធិបតី ឬពីនាយករដ្ឋមន្ត្រីជាព្រះរាជតំណាងតាមរយៈព្រះរាជសារប្រគល់សិទ្ធិ ។

ក្នុងករណីចាំបាច់ ឧត្តមក្រុមប្រឹក្សាការពារជាតិអាចធ្វើការប្រជុំវិសាមញ្ញតាមសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ។

**មាត្រា ៧.–**

ឧត្តមក្រុមប្រឹក្សាការពារជាតិមានសិទ្ធិអញ្ជើញរដ្ឋមន្ត្រី ឬឥស្សរជនជាន់ខ្ពស់នៃរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់ ។

**មាត្រា ៨.–**

បែបបទនិងនីតិវិធីការងាររបស់ឧត្តមក្រុមប្រឹក្សាការពារជាតិ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ឧត្តមក្រុមប្រឹក្សាការពារជាតិ ។

**មាត្រា ៩.–**

ឧត្តមក្រុមប្រឹក្សាការពារជាតិ ត្រូវមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាការពារជាតិ ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាការពារជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ប្រភពធនធាន

**មាត្រា ១០.-**

ការចំណាយសម្រាប់ដំណើរការរបស់ឧត្តមក្រុមប្រឹក្សាការពារជាតិ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិដោយឡែកក្នុងគម្រោងថវិការបស់ក្រសួងការពារជាតិ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ចារក.១៣០៣.២៤៣

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ទៀ បាញ់

លេខៈ២៣៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សុយ សុខា